# ព្រឹត្តិបត្រអង្គការស្ត្រីខ្មែរកម្ពុជាក្រោម

# Khmer Kampuchea Krom Women Organization Bulletin

ចេញផ្សាយប្រចាំកន្លះខែ ឆ្នាំទី២ លេខ២៧ ពីថ្ងៃទី០១-១៥ ខែកញ្ញា ឆ្នាំ២០០៩


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

## សេចក្តីថ្លែងការណ៍

ខ្ញុំ យ៉ន្ត ថារ៉ូ អ្នកតំណាងរាស្ត្រមណ្ឌលបន្ទាយមានជ័យ ក្រោយពីបានឃើញសម្តេចអគ្គមហាសង្ឃរាជាធិបតី នន់ ងែត បាននិមន្តចូលរួមជាព្រះអធិបតី នៅក្នុងពិធីបុណ្យដ៏ធំមួយនៅដែនដីកម្ពុជាក្រោម កាលពីថ្ងៃព្រហស្បតិ៍ ២រោជ ខែផល្គុន ឆ្នាំជូត សំរិទ្ធិស័ក ព.ស ២៥៥២ ត្រូវនឹងថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ និងឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងពត៌មាន បានដឹកនាំគណៈប្រតិភូទៅចូលរួមកាន់បិណ្ឌ នៅវត្តមួយចំនួននៃដែនដីកម្ពុជាក្រោម កាលពីថ្ងៃសៅរ៍ ១រោជ ខែភទ្របទ ឆ្នាំឆ្លូវ ឯកស័ក ព.ស ២៥៥៣ ត្រូវនឹងថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៩ ដោយមានការស្វាគមន៍ និងអបអរសាទរយ៉ាងក្រៃលែង ពីព្រះសង្ឃនិងបងប្អូនជនរួមឈាមខ្មែរកម្ពុជាក្រោម ដែលកំពុងរស់នៅលើទឹកដីដូនតារបស់ខ្លួន ហើយរយៈពេលជាង៣០ឆ្នាំនេះ ខ្មែរកម្ពុជាក្រោម និងខ្មែរកណ្តាលពុំដែលបានទំនាក់ទំនងគ្នាជាផ្លូវការទេ។

ពាក្យថាកម្ពុជាក្រោម ពីថ្ងៃនេះតទៅលែងជាឧបសគ្គទៀតហើយ ពីព្រោះកន្លងមកពាក្យថាកម្ពុជាក្រោម ត្រូវបានរដ្ឋាភិបាលវៀតណាមហាមឃាត់ និងចោទប្រកាន់ ដោយឱ្យប្រើពាក្យថាខ្មែរណាមបូទៅវិញ។

សកម្មភាពទាំងអស់នេះ សបញ្ជាក់ឱ្យឃើញថា ខ្មែរចេះជួយខ្មែរ ខ្មែរចេះការពារខ្មែរ ខ្មែរចេះស្រឡាញ់កេរ្តិ៍ដំណែលពីដូនតារបស់ខ្លួន ។ ដូច្នេះខ្ញុំមានសេចក្តីត្រេកអរ និងរីករាយយ៉ាងក្រៃលែង ហើយមានក្តីសង្ឃឹមយ៉ាងមុតមាំថា ចាប់ពីនេះតទៅមុខ បងប្អូនជនរួមឈាមខ្មែរនៅឯដែនដីកម្ពុជាក្រោម នឹងត្រូវបានការយកចិត្តទុកដាក់ ពីប្រមុខរាជរដ្ឋាភិបាលកម្ពុជា ស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំមានជំនឿថា បងប្អូនជនរួមឈាមខ្មែរ និងថ្នាក់ដឹកនាំនៃព្រះរាជាណាចក្រកម្ពុជា នឹងមានសកម្មភាពដ៏ល្អបែបនេះ ជាហូរហែបន្តទៅអនាគត ហើយការធ្វើបុណ្យក្តី ការទៅទេសចរណ៍ក្តី ការទៅទស្សនកិច្ចក៏ដោយ សូមឱ្យជួយនាំយកនូវសៀវភៅក្បួនខ្នាតជាអក្សរសាស្ត្រខ្មែរ ទៅចែកជូនដល់បងប្អូនជនរួមឈាមនៃយើង ដែលកំពុងរស់នៅឯដែនដីកម្ពុជាក្រោម សំរាប់ការសិក្សារៀនសូត្រ ដើម្បីជាឧត្តមប្រយោជន៍នៃមាតុភូមិរបស់យើង។



ឯកឧត្តម យ៉ន្ត ថារ៉ូ
ដឹកទឹកសម្បថនៅ
ព្រះបរមរាជវាំង
ពេលចូលសច្ចាប្រណិធាននាពេលកន្លងមក

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩

យ៉ន្ត ថារ៉ូ
អ្នកតំណាងរាស្ត្រមណ្ឌលបន្ទាយមានជ័យ
០១១ ៩៧ ៩៥ ៩៣ / ០១២ ៤៨ ១១ ៦១




អាសយដ្ឋាន: ផ្ទះលេខ១១៩ ផ្លូវ២៩៤ ក្រុម៦៨ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ: ០១១ ៧១ ២៣ ២៥ / ០១១ ៦៣ ៦០ ១២
E-mail: kkkwo@yahoo.com


ចែកជូនដោយឥតគិតថ្លៃ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

**សូមជម្រាបជូន**

**ឯកឧត្តម ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**តាមរយៈ** : សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា

**កម្មវត្ថុ** : សំណើចាត់វិធានការដល់អគ្គកុងស៊ុលខ្មែរ ប្រចាំទីក្រុងព្រៃនគរ ឱ្យជួយដោះស្រាយដល់ខ្មែរកម្ពុជាក្រោម។

តាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម** ជ្រាបថា តាមពត៌មានពីខ្មែរកម្ពុជាក្រោម បានឱ្យដឹងថាថ្មីៗនេះ នៅឃុំអាង ស្រុកទិនបៀង ខេត្តមាត់ជ្រូក កម្ពុជាក្រោម មានដីកព្រៃមួយខ្សែទទឹង៥០ម៉ែត្រ និងបណ្តោយ១០គីឡូម៉ែត្រ អស់ដីស្រែជាង***៤០០ហិចតា*** ក្នុងនោះមានប្រជាពលរដ្ឋ៤០០គ្រួសារ កំពុងប្រឈមមុខនឹងការបាត់បង់ដី។ ការឃើចាប់ទាំងនោះ មានប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមជាង៤០នាក់ បានតវ៉ាទាមទាររកយុត្តិធម៌។ តួរឱ្យសោកស្តាយដែលអាជ្ញាធរខេត្ត បានបញ្ជាកងកម្លាំង ក្នុងនោះមានទាហានពី៣៣០ ទៅ៣៥០នាក់ និងនគរបាល២៣០នាក់ ព្រមទាំងមានសត្វឆ្កែដ៏កាចសាហាវជក្បាលទៀត បានគំរាមកំហែង និងបង្ក្រាបប្រជាពលរដ្ឋយ៉ាងឃោរឃៅព្រៃផ្សៃជាទីបំផុត។ តាមពត៌មាន នៃការតវ៉ារបស់បងប្អូនខ្មែរដែលជាម្ចាស់ដីធ្លីនោះ មានចំនួនតិចតួច ចំណែកកងកម្លាំងរបស់អាជ្ញាធរមានចំនួនហួសប្រមាណ។ ការសកម្មភាពបែបនេះ សបញ្ជាក់ឱ្យឃើញថា បានរំលោភសិទ្ធិមនុស្ស និងរំលោភយកដីធ្លីពីជនជាតិខ្មែរ ដែលជាម្ចាស់ដើមនៃទឹកដី ហើយពួកគាត់កំពុងប្រឈមមុខនឹងការបាត់បង់ដីធ្លី។ ម្យ៉ាងវិញទៀត ពួកគាត់កំពុងទន្ទឹងរង់ចាំការជួយអន្តរាគមន៍ពីរដ្ឋាភិបាលខ្មែរជាបន្ទាន់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម** ចាត់វិធានការទៅអគ្គកុងស៊ុលខ្មែរ នៅទីក្រុងព្រៃនគរឱ្យមានការស៊ើបអង្កេត ហើយជួយដោះស្រាយដោយសេចក្តីអនុគ្រោះ ដើម្បីជាឧត្តមប្រយោជន៍នៃជនរួមឈាមខ្មែរយើង។

សូម **ឯកឧត្តម** ទទួលនូវការស្រឡាញ់រាប់អានដ៏ស្មោះស្ម័គ្របំផុត អំពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩

យ៉ន្ត ថារ៉ូ
អ្នកតំណាងរាស្ត្រមណ្ឌល
បន្ទាយមានជ័យ

លេខ :..០៤៥៦៣..រស

បានឃើញ និងបញ្ជូនមក
**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ** "ដើម្បីមុខការ" ។
ភ្នំពេញ, ថ្ងៃទី..១៣..ខែកញ្ញា ឆ្នាំ២០០៩
**ប្រធានរដ្ឋសភា**

សម្តេចអគ្គមហាពញាចក្រី ហេង សំរិន

**ចម្លងជូន**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានរដ្ឋសភា_ព្រឹទ្ធសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ស្ថានទូតនានាប្រចាំកម្ពុជា
- អង្គការសិទ្ធិមនុស្សជាតិ_អន្តរជាតិ
- សារពត៌មានជាតិ_អន្តរជាតិ
- ឯកសារ_កាលប្បវត្តិ

ព្រឹត្តិបត្រអង្គការស្ត្រីខ្មែរកម្ពុជាក្រោម

Khmer Kampuchea Krom Women Organization Bulletin

ចេញផ្សាយប្រចាំអឌ្ឍមាស ឆ្នាំទី២ លេខ២៨ ពីថ្ងៃទី១៦-៣០ ខែកញ្ញា ឆ្នាំ២០០៩

# ខ្មែរកម្ពុជាក្រោមអបអរសាទរពិធីបុណ្យសែនដូនតា និងពិធីបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរ ឆ្នាំ២០០៩

នៅថ្ងៃព្រហស្បតិ៍ ១៣រោជ ខែភទ្របទ ឆ្នាំឆ្លូវ ឯកស័ក ព.ស២៥៥៣ ត្រូវនឹងថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ បងប្អូនខ្មែរកម្ពុជាក្រោមប្រមាណជាង៣០០នាក់ បានមកជួបជុំនៅភូមិគ្រឹះ**ឯកឧត្តម យន្ត ថារ៉ូ** ដើម្បីអបអរសាទរពិធីបុណ្យសែនដូនតា និងពិធីបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរ ដោយមាននិមន្តព្រះសង្ឃចំនួន០៧អង្គ មកពីវត្តសំរោងអណ្តែត និងវត្តតាំងកសាងខាងជើង។

ជាកិច្ចចាប់ផ្តើមកម្មវិធីលោកតាអាចារ្យបានធ្វើកិច្ចការប្រពៃណីតាមព្រះពុទ្ធសាសនា ដោយមាននមស្សការ សមាទានសីល និមន្តព្រះសង្ឃចំរើនព្រះបរិត្ត ដារបង្សុកូល ឧទ្ទិសមគ្គផលជូនបុព្វការីជន និងញាត្តិការទាំង៧សន្តាន។ ទន្ទឹមនឹងព្រះសង្ឃកំពុងទទួលភត្តាហារនោះ អ្នករៀបចំកម្មវិធីបានអញ្ជើញ **ឯកឧត្តម យន្ត ថារ៉ូ** មានមតិសំណេះសំណាលជាមួយព្រះសង្ឃ និងបងប្អូនខ្មែរកម្ពុជាក្រោម ដែលមានចំណុចសំខាន់ៗដូចតទៅ។

ឯកឧត្តមបានមានប្រសាសន៍ថា ការប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌមានរយៈពេល១៥ថ្ងៃ នៅឯកម្ពុជាក្រោមមានចំណុចមួយចំនួនដូចគ្នានៅនឹងព្រះរាជាណាចក្រកម្ពុជាដែរ ប៉ុន្តែឯកឧត្តមមិនអត្ថាធិប្បាយទេ អត្ថាធិប្បាយតែអ្វីដែលប្លែកគ្នានោះគឺនៅកម្ពុជាក្រោម ចាប់ពីថ្ងៃ១រោជ រហូតដល់ថ្ងៃ១៣រោជ គេហៅថា បុណ្យកាន់បិណ្ឌ ឬបុណ្យដាក់វេណ ពិធីនេះពុទ្ធបរិស័ទខ្មែរនៅកម្ពុជាក្រោម និមន្តព្រះសង្ឃមកឆាន់នៅតាមផ្ទះ ឧទាហរណ៍: ក្នុងវត្តមួយមានព្រះសង្ឃ១០០អង្គ ហើយមាន១០ភូមិ គណៈកម្មការវត្តនឹងចាត់ចែងព្រះសង្ឃទាំងអស់អង្គនោះទៅភូមិនីមួយៗ តាមភូមិតូច ភូមិធំ។ ដោយឡែកថ្ងៃ១៤រោជ ខែភទ្របទ គឺជាថ្ងៃសែនដូនតា ម្ល៉ោះហើយនៅតាមផ្ទះនីមួយៗគេមានការសែនព្រេនដល់ជីដូន-ជីតា ញាត្តិការទាំង៧សន្តានផង និង និមន្តព្រះសង្ឃមកឆាន់នៅផ្ទះផង។ ទោះបីគ្រួសារខ្លះបាននិមន្តព្រះសង្ឃមកឆាន់នៅផ្ទះ ក្នុងចន្លោះពីថ្ងៃទី១ដល់ថ្ងៃទី១៣ហើយក៏ដោយ ក៏នៅថ្ងៃសែនដូនតាត្រូវតែនិមន្តព្រះសង្ឃមកឆាន់នៅផ្ទះដដែល។ ដូច្នេះនៅថ្ងៃបុណ្យសែនដូនតាព្រះសង្ឃនៅកម្ពុជាក្រោមពុំគ្រប់តាមសេចក្តីត្រូវការរបស់ពុទ្ធបរិស័ទទេ មានព្រះសង្ឃអង្គខ្លះក្នុងមួយថ្ងៃត្រូវទៅឆាន់តាមផ្ទះ ពី៥ទៅ៧ផ្ទះ ហើយតាមទំនៀមទំលាប់ខ្មែរនៅកម្ពុជាក្រោម ការនិមន្តព្រះសង្ឃសូត្រមន្ត ឬឆាន់យ៉ាងតិចចាប់ពី៤អង្គឡើងទៅ ពីព្រោះបើមិនគ្រប់៤អង្គទេ តាមក្បួនព្រះពុទ្ធសាសនាមិនហៅថាសង្ឃឡើយ។ លក្ខណៈពិសេសមួយទៀតនៅថ្ងៃ១៤រោជនោះ គឺក្មេងៗត្រូវតែត្រៀមស្មៅគោ ក្របី ចំណីសត្វឱ្យបានគ្រប់គ្រាន់ក្នុងចន្លោះពីរឬបីថ្ងៃ ហើយយកប្រេងដូង និងអំបោះក្រហមទៅចងលើស្នែងគោ-ក្របី ដោយប្រើពាក្យសុំខមាទោសដល់សត្វទាំងអស់នោះ ដែលខ្លួនតែងតែវាយជេរប្រទេចក្នុងរយៈកាលកន្លងមក សុំកុំឱ្យមានបាបៗ រួចបន្ទាប់មកទៀតត្រូវយកនំចំណី ធូបទាន ទៅជូនអ្នកមានគុណ វេលនោះនៅទិដ្ឋភាពតាមភូមិនីមួយៗឃើញមានព្រះសង្ឃនិមន្តពាសពេញតាមដងផ្លូវ ពីភូមិមួយទៅភូមិមួយ និងមានមនុស្សម្នាស្លៀកពាក់ខោអាវថ្មីៗ ខ្លះដើរ ខ្លះជិះកង់ ខ្លះជិះម៉ូតូ ខ្លះបីកូនឆ្លងអូរ ឆ្ពោះទៅផ្ទះអ្នកមានគុណ ដើម្បីធ្វើកិច្ចវត្តដល់លោកយាយ លោកតា លោក-ឪពុក អ្នកម្តាយ អ៊ុំ ពូ មាមីង និងបងៗ។ បន្ទាប់ពីពិធីធ្វើកិច្ចវត្តរួចការជួបជុំគ្នាដ៏ច្រើនកុះករបែបនេះ ក៏មានការជប់លៀងពិសារអាហាររួមគ្នាសប្បាយរីករាយ អបអរសាទរបុណ្យសែនដូនតាមួយឆ្នាំមានម្តងគួរឱ្យចាប់អារម្មណ៍យ៉ាងក្រៃលែង។ ចំពោះថ្ងៃ១៥រោជ ខែភទ្របទ គឺជាថ្ងៃបុណ្យ ភ្ជុំបិណ្ឌឬបុណ្យធំ ទើបពុទ្ធបរិស័ទគ្រប់ចតុទិស គ្រប់ភូមិឋាន ទាំងក្មេង ទាំងចាស់នាំគ្នាយកចង្ហាន់ទៅវត្តប្រគេនដល់ព្រះសង្ឃ ជួបជុំគ្នាយ៉ាងគគ្រឹកគគ្រេងពេញទីធ្លានៃវត្តនីមួយៗ។ ចាស់ៗសំពះលោកសូត្រមន្តទេសនា អាចារ្យសូត្រគម្ពីតម្រា កំណាព្យឃ្លាឃ្លោង រីឯក្មេងៗនៅតាមទីធ្លា លេងល្បែងប្រជាប្រិយកំសាន្ត តាំងពីព្រឹករហូតដល់រសៀល ទើបបញ្ចប់កម្មវិធីបុណ្យភ្ជុំបិណ្ឌ។ លុះស្អែកឡើងថ្ងៃ១កើត ខែអស្សុជ ពុទ្ធបរិស័ទបានយកចង្ហាន់ទៅប្រគេនដល់ព្រះសង្ឃដែលនិយមហៅថា បុណ្យជូនដូនតា ដូច្នេះពិធីបុណ្យភ្ជុំបិណ្ឌបានចាប់សព្វគ្រប់ដោយបរិបូរណ៍ ក្នុងថ្ងៃ១កើតខែអស្សុជនេះឯងជារៀងរាល់ឆ្នាំ។ ហើយអ្វីទាំងអស់ដែលរៀបរាប់មកខាងលើ វាបានរសាត់រសាយទៅសឹងអស់ទៅហើយ មិនបាននៅគ្រប់ជ្រុងជ្រោយដូចកាលពីមុនទេ ពីព្រោះប្រជាពលរដ្ឋខ្មែរនៅដែនដីកម្ពុជាក្រោមជួបនូវឧបសគ្គមួយចំនួនដូចជា វិបត្តិសេដ្ឋកិច្ច និងការរឹតបណ្តឹងពីអាជ្ញាធរវៀតណាមបានជះឥទ្ធិពលដល់ប្រជាពលរដ្ឋខ្មែរយ៉ាងខ្លាំងក្លាជាទីបំផុត ក្នុងការភ័យខ្លាចនៃការគ្រប់គ្រង និងចាត់ចែងការងារក្នុងវត្តអារាមនីមួយៗ ក៏ដូចជាប្រជាពុទ្ធបរិស័ទនៅតាមភូមិ មានន័យថាបើនរណាម្នាក់ធ្វើចេះធ្វើដឹង គិតគូរដល់ប្រយោជន៍សាធារណៈខ្មែរកម្ពុជាក្រោមត្រូវបានបក្ស និងរដ្ឋវៀតណាមកត់សំគាល់ថា អ្នកនោះស្នេហាជាតិ អ្នកនោះមាន គំនិតមិនស្មោះត្រង់ជាមួយបក្សនិងរដ្ឋ ច្បាស់ជាថ្ងៃណាមួយត្រូវបានសមត្ថកិច្ចចោទប្រកាន់ពីបទក្បត់បក្សជាក់ជាពុំខាន នេះគឺជាមេរៀនដែលបងប្អូនជនរួមឈាមខ្មែរកម្ពុជាក្រោមចាំមិនភ្លេច។ ម្ល៉ោះហើយអ្វីៗដែលជាប្រពៃណីខ្មែរនៅកម្ពុជាក្រោម ត្រូវបានបាត់បង់ជាបន្តបន្ទាប់ក្នុងរយៈកាល៦០ឆ្នាំចុងក្រោយនេះ។

បន្ទាប់ពី**ឯកឧត្តម យន្ត ថារ៉ូ** មានមតិសំណេះសំណាលចប់ បងប្អូនបានពិសារអាហារមិត្តភាពរួមគ្នាក្នុងនាមជាមហាគ្រួសារខ្មែរកម្ពុជាក្រោម អមដោយមានចាក់ខ្សែវីដេអូប្រពៃណីទំនៀមទំលាប់របស់ខ្មែរកម្ពុជាក្រោម និងឯកសារដែល **ឯកឧត្តម ខៀវ កាញារិទ្ធ និងលោកជំទាវ** ព្រមទាំងសហការី បានទៅដល់ដែនដីកម្ពុជាក្រោម ដែលជាមាតុភូមិរបស់យើងទាំងអស់គ្នា។






ទិដ្ឋភាពនៃការជួបជុំគ្នា ក្នុងពេលប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរ នាថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩



រាល់ការជួយឧបត្ថម្ភលោះពុម្ពព្រឹត្តិបត្រ មេត្តាទាក់ទងលេខទូរស័ព្ទនៅទំព័រខាងលើ សូមអរគុណ